# របាយការណ៍សង្ខេប
# ស្តីពីភាពជោគជ័យក្នុងរយៈពេល ០៥ឆ្នាំ(២០១៨-២០២៣) របស់រដ្ឋបាលខេត្ត
# ដោយឯកឧត្តម អ៊ូច ភា អភិបាល នៃគណៈអភិបាលខេត្តតាកែវ!
# សម្រាប់សន្និសីទសារព័ត៌មាន ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២៣
# នៅទីស្តីការគណៈរដ្ឋមន្ត្រី

ជាបឋម ខ្ញុំបាទសូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ។

ថ្ងៃនេះ ក្នុងនាមរដ្ឋបាលខេត្តតាកែវ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមវេទិកាសន្និសីទព័ត៌មានស្តីពីវឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តតាកែវ ក្រោមការរៀបចំរបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលនេះគឺជាវេទិកាដ៏មានសារៈសំខាន់ដែលអនុញ្ញាតឱ្យក្រសួង ស្ថាប័ននានា ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ មានឱកាសបានធ្វើការផ្សព្វផ្សាយអំពីសមិទ្ធផល វឌ្ឍនភាព និងទិសដៅការងារបន្ត ក៏ដូចជាសកម្មភាព ឬព័ត៌មាននានា ជូនដល់សាធារណជនទាំងក្នុង និងក្រៅប្រទេសបានជ្រាបជាព័ត៌មាន ស្របនឹងកាលទេសបច្ចុប្បន្ន ដែលប្រជាជនកម្ពុជាទូទាំងប្រទេសកំពុងទទួលនូវមនុញ្ញផលពីកត្តាសុខសន្តិភាព និងការអភិវឌ្ឍ រីកចម្រើនលើគ្រប់វិស័យ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនអង្គសន្និសីទមេត្តាជ្រាបថា ក្នុងរយៈពេល ០៥ឆ្នាំកន្លងមកនេះ រដ្ឋបាលខេត្តតាកែវ ដោយមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាពពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទាំងខេត្តតាកែវ បានខិតខំអនុវត្តន៍បំពេញការងារលើគ្រប់វិស័យ ដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ និងកម្មវិធីវិនិយោគ ០៣ឆ្នាំរំកិល ត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្ត និងចូលរួមអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៨-២០២៣ សម្រេចបានសមិទ្ធផលជាច្រើន ក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងខេត្តតាកែវ។ ខេត្តនៅតែរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បានល្អប្រសើរ តាមរយៈការអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងដោយមានការយកចិត្តទុកដាក់ជាប់ជាប្រចាំរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តតាកែវ។

ក្នុងឱកាសពោរពេញដោយក្តីសោមនស្សរីករាយ និងមានសារៈសំខាន់នេះផងដែរ ខ្ញុំសូមអញ្ញាតរាយការណ៍ជូនដោយសង្ខេបអំពីស្ថានភាពភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច វប្បធម៌ និងការវិវឌ្ឍន៍ប្រែប្រួលនៃប្រជាពលរដ្ឋខេត្តតាកែវ ជូនអង្គសន្និសីទទាំងមូលបានជ្រាបដូចតទៅ៖

## ១-ទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ៖

ខេត្តតាកែវ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ស្ថិតនៅប៉ែកនិរតី នៃព្រះរាជាណាចក្រកម្ពុជា មានចំងាយ ៧៧គីឡូម៉ែត្រ តាមផ្លូវជាតិលេខ២ និង៨៧គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៣ និងមានប្រវែង ៧៥គីឡូម៉ែត្រ តាមផ្លូវដែកពីរាជធានីភ្នំពេញ។ មានព្រំប្រទល់ខាងជើង និងខាងកើតជាប់ខេត្តកណ្តាល ខាងលិចជាប់ខេត្តកំពង់ស្ពឺ និងខេត្តកំពត និងខាងត្បូង ខាងកើតជាប់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ស្ថានភាពផ្ទៃដីមានលក្ខណៈវាលទំនាប និងដីខ្ពស់ជាប់ជួរភ្នំ មានផ្ទៃដីសរុប **៣.៦៨០,១៥**គីឡូម៉ែត្រការ៉េ មាន**១០**ក្រុង ស្រុក **១០០**ឃុំ សង្កាត់ និងភូមិ **១.១២១**ភូមិ មានប្រជាពលរដ្ឋសរុបចំនួន **១.០៥៣.៩៩៧**នាក់ ស្ត្រី **៥៤២.៤៧៧**នាក់ ស្មើនឹង **២៣៣.៨៧៧**គ្រួសារ និងមានដង់ស៊ីតេ **២៧០**នាក់/គ.ម$^{២}$។ ក្នុងអាណត្តិទី៦ របស់រដ្ឋសភា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ** ប្រជាពលរដ្ឋខេត្តតាកែវ មានចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ(GDP)កើនឡើងជាលំដាប់ចាប់ពី**១.៣៦៤**ដុល្លារ/ម្នាក់នៅឆ្នាំ២០១៨ ទៅដល់**១.៥២៦**ដុល្លារ/ម្នាក់ នៅឆ្នាំ ២០២១ ។

ខេត្តមានច្រកទ្វារព្រំដែន **០៣**កន្លែង គឺទី១.ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន ទី២.ច្រកទ្វារព្រំដែនទ្វេភាគីកំពង់ក្រសាំង និងទី៣.ច្រកទ្វារតំបន់ព្រំដែនបាក់ដៃ ដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរ ការដឹកជញ្ជូនទំនិញ និងការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនតាមច្បាប់កំណត់។ ដោយផលប៉ះពាល់នៃជំងឺកូវីដ-១៩ ដែលបានកំពុងរីករាលដាលនៅទូទាំងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជាយើងផងដែរ ការដោះដូរផ្ទេរទំនិញ រវាងភាគីទាំងពីរមានដំណើរការជាធម្មតានៅតាមច្រកទ្វារព្រំដែនដោយអនុវត្តន៍យ៉ាងម៉ឹងម៉ាត់តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងវិធានការណែនាំរបស់ក្រសួងសុខាភិបាល។

## ២.ការងារគ្រប់គ្រងរដ្ឋបាល

បន្ទាប់ពីទទួលបានការធ្វើសមាហរណកម្មការិយាល័យជំនាញនានាជុំវិញក្រុង ស្រុក ទៅក្នុងរចនាសម្ព័ន្ធថ្មី តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្ត បានទទួលការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ពីការិយាល័យជំនាញនានាជុំវិញក្រុង ស្រុក ទៅក្នុងរចនាសម្ព័ន្ធថ្មី សរុបចំនួន **៩៣១** នាក់ ស្រី **២០៩**នាក់។ រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុក ទទួលបានការធ្វើប្រតិភូកម្មអំណាចពីក្រសួង និងស្ថាប័នថ្នាក់ជាតិតាមវិស័យមួយចំនួនក្នុងការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយថ្នាក់ខេត្ត និងការិយាល័យច្រកចេញចូលតែមួយថ្នាក់ក្រុង ស្រុក និងកំពុងបន្តទៅថ្នាក់ឃុំ សង្កាត់ ទាំង១០០ ទូទាំងខេត្ត។

អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត បានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ មានមន្ទីរ អង្គភាព បានធ្វើប្រតិភូកម្មមុខងារចំនួន **១៤**វិស័យ។ ក្នុងរយៈពេល ០៥ឆ្នាំនេះ(២០១៨-២០២២)អង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្ត បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុបចំនួន **១២៥.១៦៧**នាក់ ក្នុងនោះស្ត្រីមកទទួលសេវាមានចំនួន **៣៩.១៦០**នាក់ និងទទួលចំណូលសរុបចំនួន **១៥.៦៤៥.០០៨.៩៦៩**រៀល។

ក្នុងរយៈពេល ០៥ឆ្នាំកន្លងមកនេះ ខេត្តតាកែវបានអនុវត្តន៍នូវគម្រោងវិនិយោគ ៣ឆ្នាំរំកិល សម្រេចបាន ចំនួន **១.១៣១**គម្រោង ចំណាយថវិកាសរុបចំនួន **២.៣៣១ប៊ីលាន.៨៣៦.៣៦០.០០០**រៀល អនុវត្តន៍ការ ចំណាយដោយថវិកាជាតិ។

## ៣.ការខារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

សភាពការណ៍សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងភូមិសាស្ត្រខេត្តតាកែវ និងនៅ តាមតំបន់ព្រំដែនមានភាពល្អប្រសើរ ដែលនេះស្តែងឱ្យឃើញពីការខិតខំប្រឹងប្រែងបំពេញការងាររបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក និងគ្រប់លំដាប់ថ្នាក់ទាំងអស់នៅក្នុងខេត្ត។ បទល្មើសដែលកើតឡើងត្រូវបានប ង្ក្រាបជាបន្តបន្ទាប់ សន្តិសុខសណ្តាប់ធ្នាប់ត្រូវបានធានា និងពង្រឹង។ បទល្មើសព្រហ្មទណ្ឌនៅក្នុងខេត្តកើតឡើង ចំនួន **៩៩៥**ករណី បង្ក្រាបជាក់ស្តែងបានចំនួន **៩៧៩**ករណី ចាប់ខ្លួនបានចំនួន **១.១៧៦**នាក់ ស្មើនឹង **៩៨%** បង្ក្រាបតាមដីកាបានចំនួន **៨៦**ដីកា បង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន **៦៨៩**ករណី ចាប់ឃាត់ខ្លួនបានចំនួន **៩៤៧**នាក់ ស្រី **៤៦**នាក់ ក្នុងនោះជួញដូរ និងចែកចាយចំនួន **៥៤៤**ករណី ឃាត់ខ្លួនបានចំនួន **៩០៣**នាក់ស្រី **៤៦** នាក់ ករណីដាំដុះ និងប្រើប្រាស់មានចំនួន **១៤៥**ករណី ឃាត់ខ្លួនមនុស្សបានចំនួន **៤៤**នាក់ បង្ក្រាបតាមដីកាបាន ចំនួន **១០១**ដីកា ឃាត់ខ្លួនមនុស្សបានចំនួន **១០១**នាក់ ស្រី **០៤**នាក់ បទល្មើសល្បែងស៊ីសងចំនួន **៦១**ករណី ឃាត់ ខ្លួនមនុស្សចំនួន **១៥២**នាក់ ស្រី **១៤**នាក់ ក្នុងនោះធ្វើកិច្ចសន្យាអប់រំចំនួន **៥៤**ករណី និងបញ្ជូនទៅតុលាការចំនួន **៧**ករណី បង្ក្រាបក្មេងទំនើងចំនួន **៦៦**ករណី ឃាត់ខ្លួនបានចំនួន **១៩៣**នាក់ ក្នុងនោះធ្វើកិច្ចសន្យាអប់រំចំនួន **៥៧** ករណី និងបញ្ជូនទៅតុលាការចំនួន **៩**ករណី។ គ្រោះថ្នាក់សង្គមកើតឡើងចំនួន **១.៣៤១**ករណី ក្នុងនោះគ្រោះថ្នាក់ ចរាចរណ៍ចំនួន **៤១៦**លើក មនុស្សស្លាប់ **២៨៨**នាក់ របួស **៨៩៥**នាក់ អាវុធជាតិផ្ទុះកើតឡើង **០២**លើក ស្លាប់**០១** នាក់ របួស**០១**នាក់ គ្រោះអគ្គិសភ័យកើតឡើងចំនួន **១៤១**លើក ស្លាប់**០៤**នាក់ របួស **០៥**នាក់ ឆេះគូបចំនួន **៥០៣** គូប ឆេះផ្ទះចំនួន **៨២**ខ្នង ខ្យល់ព្យុះកើតឡើងចំនួន **១២៧**លើក ស្លាប់មនុស្ស **០១**នាក់ របួស **២២**នាក់ របើកដំបូល **១.៥២៩**ខ្នង រលំផ្ទះចំនួន **២៨២**ខ្នង រន្ទះបាញ់ចំនួន **២៧**លើក ស្លាប់មនុស្ស **១៩**នាក់ របួស **០៦**នាក់ អត្តឃាតកើត ឡើង **២៤០**លើក ស្លាប់មនុស្ស **២៣៨**នាក់ របួស **០២**នាក់ និងករណីផ្សេងៗកើតឡើងចំនួន **៣៨៨**លើក ស្លាប់ **៣៨៨** នាក់ របួស **៣១៦**នាក់។ ជាមួយគ្នានេះដែរ ខេត្តបានរក្សាទំនាក់ទំនងយ៉ាងល្អជាមួយភាគីវៀតណាម តាមរយៈការជួបប្រជុំ ពិភាក្សាដើម្បីផ្លាស់ប្តូរព័ត៌មាន និងបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរ។ ទន្ទឹមនឹងនេះកងកម្លាំងរក្សាសន្តិសុខ ព្រំដែនក៏បានសហការជាមួយភាគីវៀតណាមដើម្បីទប់ស្កាត់នូវបទល្មើសនានាដែលកើតឡើងនៅតាមព្រំដែនផង។

ខេត្តបានរៀបចំធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ ដើម្បីដោះស្រាយបញ្ហា សំណើរ និងសំណូមពររបស់ ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងការអនុវត្តន៍គោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ព្រមទាំងខិតខំដោះ ស្រាយនូវបញ្ហាប្រឈមនានាដែលកើតឡើង ដើម្បីផ្តល់ព័ត៌មានឆ្លើយតបឱ្យបានសមស្របទៅប្រជាពលរដ្ឋជាក់ស្តែង។ ក្នុងរយៈពេលប ០៥ឆ្នាំនេះ ខេត្តបានរៀបចំធ្វើការផ្សព្វផ្សាយវេទិកាសារធារណៈចំនួន **១៧.៧២៩**លើក មានប្រជា ពលរដ្ឋចូលរួមសរុបចំនួន **៧៤០.២១១**នាក់ ស្រី **៣៥០.១៣១**នាក់ និងកំលាំងប្រជាការពារចូលរួមសរុបចំនួន **៣៧.៩៥១**នាក់។

លទ្ធផលការប្រឡងប្រណាំងភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្តតាកែវ ឆ្នាំ២០២២ ចំណាត់ថ្នាក់លេខ១ មានចំនួន **៦៤**ឃុំ សង្កាត់ លេខ២ មានចំនួន **៣៦**ឃុំ សង្កាត់ ធៀបនឹងឆ្នាំ២០១៨ ចំណាត់ថ្នាក់លេខ១ មានចំនួន **៤៣**ឃុំ សង្កាត់ លេខ២ មានចំនួន **៥៦**ឃុំ សង្កាត់ និងលេខ៣ មានចំនួន **០១**ឃុំ សង្កាត់។ បានផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋបានចំនួន **១២២.០១១**សន្លឹក សៀវភៅគ្រួសារចំនួន **៥១.៩៧៣**គ្រួសារ និងសៀវភៅស្នាក់នៅចំនួន **៤៩.០៤៦**គ្រួសារ។

## ៤.វិស័យកសិកម្ម និងធនធានទឹក

ដោយមានកត្តាអំណោយផលពីធម្មជាតិ អាកាសធាតុ សណ្ឋានដី ដីជីវជាតិ និងប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ធ្វើឱ្យខេត្តតាកែវជាប់ជាខេត្តជង្រុកស្រូវទី២ នៃព្រះរាជាណាចក្រកម្ពុជា។ ខេត្តមានប្រព័ន្ធធារាសាស្រ្តកសិកម្មសរុបចំនួន ១៣០ប្រព័ន្ធ ក្នុងនោះមានប្រព័ន្ធធំចំនួន **០៧**កន្លែង ប្រព័ន្ធមធ្យមចំនួន **៦៤**កន្លែង និងប្រព័ន្ធតូចចំនួន **៥៩**កន្លែង ហើយមានសក្តានុពលស្រោចស្រពស្រូវរដូវប្រាំងបានចំនួន **១៣៨.១៨៣**ហត និងស្រូវរដូវវស្សាចំនួន **៤៦.៦១៧**ហត។ ខេត្ត មានអាងទឹកចំនួន **៩៤**កន្លែង មានប្រវែងសរុប **២១៩.៦៨៦**ម៉ែត្រ ក្នុងនោះទំនប់ការពារទឹកជំនន់ចំនួន **០១**កន្លែង ប្រវែង **២៣.៤០០**ម៉ែត្រ ប្រឡាយមេសរុបចំនួន **៩២៧.៤២៨**ម៉ែត្រ ប្រឡាយរងប្រវែង **១៤៦.១៣៥**ម៉ែត្រ និងស្ថានីយបូមទឹកចំនួន **៣៥**កន្លែង ក្នុងនោះអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានចំនួន ០៤កន្លែង រួមមានស្ថានីយទី៧, ៨, ២២ និងស្ថានីយទី**២៣** ស្ថិតនៅស្រុកបាទី។

ក្នុងរយៈពេល **៥ឆ្នាំ** នេះការងារបង្កបង្កើនផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំងសម្រេចបានផ្ទៃដីសរុប **១.៥៦៩.២៨៦** ហត បរិមាណផលសរុបចំនួន **៦.១៤៧.២៩៦** តោន និងបរិមាណស្រូវនៅសល់សម្រាប់ធ្វើការ នាំចេញទៅរាជធានីភ្នំពេញ និងប្រទេសវៀតណាមតាមច្រកព្រំដែនសរុបចំនួន ៤.**១៤១.២៣៣**តោន។ ផ្ទៃដីដំណាំរួមផ្សំមានចំនួន ៤.០០០ហត ក្រៅពីនេះមានផ្ទៃដីលំនៅដ្ឋាន ផ្ទៃដីបឹង ស្ទឹងប្រឡាយ ដីទំនេរ ដីគម្របព្រៃឈើ និងសំណង់សាធារណៈផ្សេងៗ។

ក្រៅពីនេះយើងបានជំរុញចលនាចិញ្ចឹមសត្វ ចិញ្ចឹមត្រីចិញ្ចឹមបង្កង ទាំងនៅតាមសហគមន៍ និងនៅតាមស្រះរបស់ប្រជាពលរដ្ឋ និងឡភ្ញាស់ពងទាកូនឱ្យមានសកម្មភាពយ៉ាងផុលផុសផងដែរ។ បច្ចុប្បន្ននៅក្នុងខេត្ត មានស្រះចិញ្ចឹមត្រីកំពុងដំណើរការចំនួន **៩.១៥៥**ស្រះ កសិដ្ឋានចិញ្ចឹមជ្រូកចំនួន **៥២** កន្លែង កសិដ្ឋានចិញ្ចឹមគោចំនួន **០២** កន្លែង កសិដ្ឋានចិញ្ចឹមបក្សីចំនួន **៣៧**កន្លែង កសិដ្ឋានចិញ្ចឹមមាន់មានចំនួន **៣២**កន្លែង ឡភ្ញាស់កូនមាន់ចំនួន **០២** កន្លែង និងឡភ្ញាស់ពងទាកូនចំនួន **៧៦**កន្លែង បរិមាណស៊ុតទា(សាប ប្រៃ និងកូន)នាំចេញទៅកាន់ទីផ្សារក្នុងខេត្ត និងក្រៅខេត្តបានចំនួន **៣៤២.០០០**ពង/ថ្ងៃ មានកសិដ្ឋានចិញ្ចឹមបង្កងចំនួន **១០**កន្លែង និងបរិមាណផលបង្កងមានក្នុងមួយឆ្នាំសរុប **៦៧**តោន រយៈពេល៥ឆ្នាំបរិមាណផលចំនួន **៣៣៥** តោន។

ផ្ទៃព្រៃលិចទឹកសរុបចំនួន ២.៤៧៨ហត សហគមន៍នេសាទមានចំនួន ១៩សហគមន៍ ស្រះជំរកត្រីសហគមន៍មានចំនួន ៧៦កន្លែង និងកន្លែងអភិរក្សត្រីមេពូជសហគមន៍មានចំនួន ១៧កន្លែង។

## ៥.វិស័យពាណិជ្ជកម្ម និងការវិនិយោគ

ក្រុមហ៊ុនវិនិយោគ និងរោងចក្រធំៗនៅក្នុងខេត្តមានដូចជារោងម៉ាស៊ីនកិនស្រូវខ្នាតធំមានចំនួន **០២**កន្លែង នៅក្រុងដូនកែវ និងស្រុកត្រាំកក់ រោងចក្រ សហគ្រាសធុនធំមានចំនួន **៨៣**កន្លែង ប្រើកម្លាំងពលកម្មសរុបចំនួន **៥៦.៣៧៧**នាក់ ស្រ្តី **៤៤.០០២**នាក់ រោងចក្រធុនតូច មធ្យម និងសិប្បកម្មកំពុងដំណើរការដែលបានសុំប្រកាសពី

ក្រសួង និងចុះបញ្ជីនៅមន្ទីរ(មូលដ្ឋាន)មានចំនួន **៥៧៧**កន្លែង ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន **៧.៦៤៥**នាក់ ស្ត្រី **៤.៦៥៣**នាក់។ ខេត្តតាកែវ មានស្រុកចំនួន **០៣** ដែលមានសិប្បកម្មប្រពៃណីផលិតហូលផាមួង មានកីតម្បាញចំនួន **១.២៩២**កី ដែលអាចផលិតហូល ផាមួង បានជាមធ្យម **៣.៨៧៦**ក្បិន។

## ៦.វិស័យទេសចរណ៍ និងវប្បធម៌

ខេត្តតាកែវ ជាខេត្តមួយដែលសម្បូរភោគផលធម្មជាតិ ទីតាំងប្រវត្តសាស្ត្រ វប្បធម៌ និងរមណីយដ្ឋានជាច្រើនដែលអាចទាក់ទាញភ្ញៀវទេសជាតិ និងអន្តរជាតិមកទស្សនា សម្រាកលំហែកាយ និងកំសាន្តនៅតាមតំបន់ទេសចរណ៍នានា ទាំងតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់ទេសចរណ៍កែច្នៃ វប្បធម៌ និងប្រវត្តិសាស្ត្រ ដែលបានទាក់ទាញកំណើនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាជារៀងរាល់ឆ្នាំ។ ខេត្តតាកែវ មានរមណីយដ្ឋាទេសចរណ៍ចំនួន **១០**កន្លែង រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន **០៥**កន្លែង រមណីយដ្ឋានធម្មជាតិចំនួន **០១**កន្លែង រមណីយដ្ឋានវប្បធម៌ធម្មជាតិចំនួន **០២**កន្លែង រមណីយដ្ឋានកែច្នៃចំនួន **០២**កន្លែង និងប្រាសាទបុរាណចំនួន **៣៦**ប្រាសាទ។ ក្នុងរយៈពេល ០៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) ខេត្តតាកែវ ទទួលបានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាសរុបចំនួន **៣.៥៦១.៩០៥**នាក់ ក្នុងនោះ ភ្ញៀវជាតិចំនួន **៣.៥២៣.៧២០**នាក់ និងភ្ញៀវអន្តរជាតិចំនួន **៣៨.១៨៥**នាក់។

ជាមួយគ្នានេះផងដែរ ខេត្តក៏មានសណ្ឋាគារចំនួន **០២**កន្លែង ផ្ទះសំណាក់ និងបន្ទប់ជួលចំនួន **១៥៦**កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋានចំនួន **១២៧**កន្លែង ខារ៉ាអូខេចំនួន ៥៨កន្លែង កន្លែងម៉ាស្សាចំនួន ០៥កន្លែង និងហាងកាហ្វេចំនួន ២៦កន្លែង ដែលកំពុងដំណើរការផ្តល់សេវាស្នាក់នៅ ចំណីអាហារ និងភេសជ្ជៈប្រកបដោយភាពកក់ក្តៅ និងមានគុណភាពជូនដល់ភ្ញៀវជាតិ និងអន្តរជាតិ។

ទន្ទឹមនឹងនេះផងដែរ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ឱ្យចូលមកទស្សនាកំសាន្តកាន់តែច្រើន ខេត្តក៏បានរៀបចំព្រឹត្តិការណ៍សំខាន់ៗជារៀងរាល់ឆ្នាំ ដូចជាពិធីសង្ក្រានដូនកែវ ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ពិធីបុណ្យអុំទូកបណ្តែតប្រទីបរបស់ខេត្ត កម្មវិធីឆ្លងឆ្នាំសកល និងពិធីតាំងពិពណ៌ផ្សេងៗជាច្រើនផងដែរ។

## ៧.វិស័យសាធារណការ និងផ្លូវជនបទ

ខេត្តតាកែវ បានបន្តការស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដោយផ្តោតសំខាន់ទៅលើការកសាង ជួសជុល ថែទាំផ្លូវជាតិ ផ្លូវខេត្ត និងបន្តកសាងផ្លូវជនបទឱ្យមានគុណភាពខ្ពស់ក្នុងគោលបំណងតភ្ជាប់បណ្តាញផ្លូវពីទីរួមខេត្តទៅស្រុក និងពីស្រុកទៅឃុំ សង្កាត់ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ខេត្ត។ បច្ចុប្បន្ននេះខេត្តមានផ្លូវជាតិ និងផ្លូវខេត្តសរុបចំនួន ៤១ខ្សែ មានប្រវែងសរុប ៧២២,៤៧គ.ម ក្នុងនោះផ្លូវជាតិឆ្លងកាត់ខេត្តមានចំនួន ០៦ខ្សែ គឺផ្លូវជាតិលេខ២, លេខ៣, លេខ២២,លេខ២៣, លេខ៣១ និងលេខ៤១ មានប្រវែងសរុប ១៦៦,៧២គ.ម ជាប្រភេទផ្លូវកៅស៊ូ និងផ្លូវខេត្តចំនួន ៣៥ខ្សែ មានប្រវែង ៥៥៥,៦៤គ.ម (ផ្លូវក្រាលកៅស៊ូមានប្រវែង ៣២៨,៩៤គ.ម ផ្លូវបេតុងប្រវែង ២២,៤១គ.ម និងផ្លូវក្រាលដីល្បាយថ្មមានប្រវែង ២០៤,៩២គ.ម)និងមានផ្លូវរថភ្លើងឆ្លងកាត់ប្រវែង ៥៦,៣៨គ.ម ដែលជាបណ្តាញដឹកជញ្ជូនទំនិញដ៏សំខាន់។ ខេត្តមានសំណង់ស្ពានសរុបចំនួន ០៨កន្លែង និងទីលានចាក់សំរាមចំនួន **០៤**កន្លែង។ ថ្មីៗនេះការកសាងកំណាត់ផ្លូវជាតិលេខ៣ ប្រវែង ៣០គ.ម នៃគម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៣ ជាជំនួយហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានបញ្ចប់ជាស្ថាពរ និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ថិតក្រោមអធិបតីភាព**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។ កំណាត់ផ្លូវជាតិលេខ២ ផ្លូវលេខ២២ នៃគម្រោងធ្វើឱ្យប្រសើរឡើងវិញ ដែលបានបើក

ការដ្ឋានសាងសង់កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ផ្លូវជាតិលេខ៤២ មានប្រវែង ៤២,៩៦គ.ម និងផ្លូវជាតិលេខ២២ ពីអូរចំបក់ ដល់អង្គតាសោម មានប្រវែង ៩,៦១គ.ម ដែលគ្រោងបញ្ចប់នៅឆ្នាំ២០២៣ ។

ក្នុងរយៈពេល០៥ ឆ្នាំនេះ ខេត្តបានកសាងផ្លូវជនបទ ទាំងក្រាលកៅស៊ូ ក្រាលក្រួសក្រហម និងក្រាលដីស ចំនួន **២៨២**ខ្សែ ប្រវែង **៨១២,១១**គ.ម ក្នុងនោះសាងសង់ និងជួសជុលជាប្រចាំផ្លូវកៅស៊ូចំនួន **០៧**ខ្សែ ប្រវែង **៦៤,០៩**គ.ម សាងសង់អណ្តូងស្នប់ចំនួន **៣១៨**អណ្តូង ផ្តល់ពាងត្រងទឹកភ្លៀងចំនួន **៥០**ពាង និងសាងសង់បង្គន់អនាម័យតាមផ្ទះបានចំនួន **៥០**បង្គន់។

## ៨-វិស័យការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម៖

ខេត្តមានសហគ្រាសគ្រឹះស្ថានកាត់ដេរសម្លៀកបំពាក់ផលិតស្បែកជើងចំនួន៦៤គ្រឹះស្ថាន និងសហគ្រាសគ្រឹះស្ថានក្រៅពីកាត់ដេរសរុបចំនួន១៦២គ្រឹះស្ថាននិងមានកម្មករកម្មការិនីសរុប៦៦.៦៤៥នាក់ស្រី៤៩.៦៦៣នាក់ ។

ខេត្តតាកែវមានមន្ត្រីរាជការ កម្មករនយោជិក និងនយោជក់សរុបចំនួន ៨៣.៤៤០នាក់ស្រី៥១.២២៦នាក់ មានសមាជិកប្រើប្រាស់សេវារបបសន្តិសុខសង្គម(បសស)សរុបចំនួន ៧៥.៩២៥នាក់ស្រី៦០.៤៧០នាក់។

រយៈពេល៥ឆ្នាំនេះ ករណីកូដកម្ម និងបាតុកម្ម កើតមានចំនួន១៩ សហគ្រាសគ្រឹះស្ថានមានចំនួន៦២លើក កម្មករកម្មការិនីចូលរួមសរុប១៣.០៨៣នាក់ បានដោះស្រាយ(សះជាចំនួន៦០ករណី)នៅសល់០២ករណី។

## ៩.វិស័យអប់រំ យុវជន និងកីឡា

គិតមកដល់ពេលបច្ចុប្បន្ន ខេត្តតាកែវមានសាលារៀនសាធារណៈគ្រប់ភូមិសិក្សាសរុបចំនួន **៨០៨**សាលា សាលាឯកជនមានចំនួន **៦០**សាលា មតេយ្យសហគមន៍មានចំនួន **១៣៥**សាលា គិតត្រឹមឆ្នាំ២០២១ខេត្តតាកែវ មានអគារសិក្សាចំនួន **១៦២២**ខ្នង ស្មើនឹង **៧.៧១៨**បន្ទប់ ក្នុងនោះអគារជាអំណោយរបស់ដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុនសែន** និងសម្តេចគតិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** មានចំនួន **៣២២**ខ្នង ស្មើនឹង**១.៨៨៩**បន្ទប់ និង អគារសិក្សាសម្តេចវិបុលបញ្ញា សុខ អាន ចំនួន **៧២**ខ្នង ស្មើនឹង**៤០០**បន្ទប់។

ចាប់ពីឆ្នាំ២០១៨-២០២២ សិស្សប្រឡងជាប់មធ្យមសិក្សាបឋមភូមិសរុបចំនួន **៥៥.៣៥៩**នាក់ ស្រី **២៩.៣៥៤**នាក់ ស្មើនឹង **៩៩,៦០%** និងមធ្យមសិក្សាទុតិយភូមិជាប់ចំនួន **៣៤.៩២៦**នាក់ ស្រី **១៨.៨១៨**នាក់ ស្មើនឹង**៩៤,៣៦%** ក្នុងនោះសិស្សជាប់និទ្ទេសA មានចំនួន **២២១**នាក់ ស្រី **១០៨**នាក់។ ក្រៅពីនេះខេត្តក៏មានសាលាគរុកោសល្យពីរ(គរុភាគ និងគរុខេត្ត) សកលវិទ្យាល័យឯកជនចំនួន **០២**កន្លែង វិទ្យាស្ថានភូមិភាគតេជោសែន **០១** កន្លែង និងវិទ្យាស្ថានឯកជន **០១**កន្លែង ។ ខេត្តមានទីលានកីឡាគ្រប់ប្រភេទចំនួន **២.៣០៤** កន្លែង សម្រាប់ហ្វឹកហាត់កីឡា និងបានបញ្ជូនសិស្សចូលរួមប្រកួតកីឡាថ្នាក់ជាតិ និងចូលរួមប្រកួងកីឡាផ្សេងៗទទួលមេដាយចំនួន **៦៨** គ្រឿង (មេដាយមាស **២៣**គ្រឿង មេដាយប្រាក់ **៣៤**គ្រឿង និងមេដាយសំរឹទ្ធ **២៩**គ្រឿង)។

## ១០.វិស័យសុខាភិបាល

ខេត្តមានមូលដ្ឋានផ្តល់សេវាសុខាភិបាលចំនួន **៩៤**កន្លែង ក្នុងនោះមន្ទីរពេទ្យបង្អែកខេត្តចំនួន**០១**កន្លែង មន្ទីរបង្អែកស្រុកចំនួន **០៦**កន្លែង មណ្ឌលសុខភាពចំនួន **៨៤**កន្លែង និងប៉ុស្តិ៍សុខភាពចំនួន **០៣**កន្លែង។ ក្រៅពីនេះ ខេត្តក៏មានមូលដ្ឋានផ្តល់សេវាឯកជនចំនួន **២២**កន្លែង និងបន្ទប់ពិគ្រោះព្យាបាលជំងឺឯកជនចំនួន **២៣៥**កន្លែង។

ខេត្តបានទទួលនូវអគារសម្ភព និងរោគស្ត្រី ដែលជាជំនួយរបស់រដ្ឋាភិបាលបារាំង និងអគារមជ្ឈមណ្ឌល ផ្តល់ឈាម និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកខេត្ត ជាជំនួយរបស់ប្រជាពលរដ្ឋអាមេរិកកាំង (តាមរយៈកងទ័ពជើងទឹកអាមេរិកកាំង)ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨។

ព្រឹត្តការណ៍ ២០ កុម្ភៈ ឆ្នាំ២០២០ បានធ្វើឱ្យមានការផ្ទុះរីករាលដាលឡើងនូវជំងឺកូវីដ-១៩ នៅទូទាំងប្រទេសកម្ពុជា។ ដោយអនុវត្តន៍តាមយុទ្ធសាស្ត្រ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ យុទ្ធសាស្ត្រមួយ ក្នុងចំណោមយុទ្ធសាស្ត្រទាំងប្រាំមួយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា គឺយុទ្ធនាការនៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទូទាំងប្រទេស។ ខេត្តបានអនុវត្តន៍យុទ្ធសាស្ត្រនេះយ៉ាងម៉ឺងម៉ាត់ ដោយបានចាក់វ៉ាក់សាំងដូសទី១ បានចំនួន **៧៦៨.៣៣១** នាក់ ដូសទី២ ចំនួន **៧៤៧.៣១៣**នាក់ ដូសទី៣ ចំនួន **៥៧៥.០០៥**នាក់ ដូសទី៤ ចំនួន **២២០.១៨៦**នាក់ ដូសទី៥ ចំនួន **៤៩.១២១**នាក់ និងដូសទី៦ ចំនួន **៣.២៩៩**នាក់។

## ១១.វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

រដ្ឋបាលខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការបានដាក់ចេញនូវផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីធានាបាននូវប្រសិទ្ធភាព និងកាត់បន្ថយនូវបញ្ហាប្រឈមនានាទាក់ទងនឹងវិស័យដីធ្លីដូចជា៖

- បានរៀបចំផែនការដែនដីខេត្តតាកែវ ដែលអនុម័តដោយរាជរដ្ឋាភិបាល និងប្លង់ប្រើប្រាស់ដីក្រុងដូនកែវ ដែលបានស្នើសុំការអនុម័តពីគណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងរាជរដ្ឋាភិបាល។

- ការងារចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធក្នុងក្របខណ្ឌកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ក្នុងរយៈពេល០៥ឆ្នាំនេះបានដំណើរការអនុវត្តក្នុងភូមិចំនួន **២៧៨**ភូមិ លើ **៣២**ឃុំ ក្នុងស្រុកចំនួន **០៥**(តាំងពីចាប់ផ្តើមអនុវត្តមកដល់បច្ចុប្បន្នមាន ៨៤ឃុំ សង្កាត់) និងបានចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋបានចំនួន **១៦៥.២២០ប័ណ្ណ**(តាំងពីចាប់ផ្តើមអនុវត្តន៍រហូតមកដល់បច្ចុប្បន្នបានចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុបចំនួន **៦៤៥.៦៨៧**ប័ណ្ណ) និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន **២៧៥**ក្បាលដី(គិតពីពេលចាប់ផ្តើមរហូតដល់បច្ចុប្បន្នបានចំនួន **៣៣.៣២០**ប័ណ្ណ)។

- ការងារអភិវឌ្ឍន៍៖ រដ្ឋបាលខេត្តបានទទួលពាក្យស្នើសុំចំនួន **២១**គម្រោង និងបានចេញលិខិតអនុញ្ញាតចំនួន **២១**គម្រោង ស្មើនឹង **១.៨៥៨**ឡូតិ៍។

- ការងារសំណង់ ៖ បានពង្រឹងការអនុវត្តវិធានការសំណង់ និងត្រួតពិនិត្យការអនុញ្ញាតសាងសង់ដោយបានចេញលិខិតអនុញ្ញាតសាងសង់ចំនួន **១៩៣**ច្បាប់ ដែលមានទុនវិនិយោគប្រមាណ **៦២៧.៥៨៤**ដុល្លាអាមេរិក។

- ការងារដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ៖ រដ្ឋបាលខេត្ត តាមរយៈគណកម្មការសុរិយោដីខេត្ត ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីជាសេនាធិការ បានខិតខំធ្វើការសម្របសម្រួលដោះស្រាយករណីទំនាស់ដីធ្លី ជូនបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។ ជាក់ស្តែងរដ្ឋបាលខេត្ត បានទទួលពាក្យបណ្តឹងសរុបចំនួន **៣២៣**ករណី បានដោះស្រាយបញ្ចប់ដោយព្រមព្រៀង **១០៧** ករណី ច្រានចោលពាក្យបណ្តឹង **១៦០**ករណី(ដោយខុសយុត្តាធិការ)ម្ចាស់បណ្តឹងដកពាក្យបណ្តឹងវិញ **៣៩**ករណី បញ្ជូនទៅស្ថាប័នថ្នាក់ជាតិ **០៥**ករណី និងកំពុងដំណើរការដោះស្រាយ **១៧**ករណី ។ ហើយថ្មីៗនេះ រដ្ឋបាលខេត្តក៏បានចូលរួមជាមួយក្រុមការងារនៃគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់លើដីធ្លី និងផលដំណាំផ្សេងៗលើគម្រោងអភិវឌ្ឍនានារបស់រាជរដ្ឋាភិបាល(គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ២ លេខ៣ និងគម្រោងសាងសង់ **អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ**)។

## ១២.វិស័យថាមពលអគ្គិសនី និងទឹកស្អាត

ខេត្តបានទទួលការផ្គត់ផ្គង់ថាមពលពីប្រព័ន្ធខ្សែបញ្ជូនជាតិ **២៣០/២២**គីឡូវ៉ុល និងពីប្រទេសវៀតណាម **២៣០**គីឡូវ៉ុល មានម៉ាស៊ីនភ្លើងបំរុងចំនួន **០៣**គ្រឿង ដែលអាចផ្គត់ផ្គង់ថាមពលចំនួន **១.៥០០**គីឡូវ៉ាត់/ម៉ោង ព្រមទាំងសេវាករចែកចាយអគ្គិសនីចំនួន **២៩**អាជ្ញាប័ណ្ណ ដែលអាចផ្គត់ផ្គង់ និងចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន **២២៩.៣៧៩**គ្រួសារ ស្មើនឹង**៩៩,៦៤%** នៃគ្រួសារសរុបទូទាំងខេត្ត។

ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន និងទីជនបទរបស់ខេត្តមានការកើនឡើងគួរឱ្យកត់សំគាល់។ សព្វថ្ងៃក្រុមហ៊ុនទឹកស្អាតឯកជនកំពុងផ្គត់ផ្គង់តាមប្រព័ន្ធបណ្តាញចំនួន **២២**មូលដ្ឋាន ដែលបានទទួលការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អាចផ្គត់ផ្គង់ទឹកស្អាតប្រមាណ **៧.៥៥១.៩៥៩**ម៣/ឆ្នាំ បានភ្ជាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន **៥៩.០៥៩**ខ្នងផ្ទះ គ្របដណ្តប់លើភូមិចំនួន **៤៦៥**ភូមិ លើ **១១២១**ភូមិ ស្មើនឹង**៤១,៥%**។

## ១៣.វិស័យព័ត៌មាន និងសោតទស្សន៍

ខេត្តមានស្ថានីយ៍វិទ្យុ និងទូរទស្សន៍(ជាតិគោកធ្លក) ជារបស់រដ្ឋ និងស្ថានីយ៍វិទ្យុឯកជនចំនួន **១១**ស្ថានីយ៍ ដែលបានចាក់ផ្សាយបន្តពីវិទ្យុទូរទស្សន៍ជាតិកម្ពុជា ជាប្រចាំនូវរាល់ព្រឹត្តិការណ៍ និងព័ត៌មានសំខាន់ៗ ស្តីពីព្រះរាជសកម្មភាពព្រះមហាសក្សត្រ ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព័ត៌មានប្លែកៗទាន់ហេតុការណ៍ និងព្រឹត្តិការណ៍ដែលកើតមានក្នុងមូលដ្ឋានខេត្ត។

## ១៤.វិស័យសង្គមកិច្ច និងសាសនា

- **ការងារសង្គមកិច្ច៖**

ការងារសាងសង់លំនៅឋានជូនគ្រួសារអតីតយុទ្ធជន ពលី ពិការ និងគ្រួសារនិវត្តជន ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការគាំទ្រពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋបាលខេត្តបានសម្របសម្រួលក្នុងការកសាងផ្ទះបានចំនួន **៦៣**ខ្នង។

អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានលើកឡើងថាយើងមិនត្រូវទុកអោយប្រជាពលរដ្ឋណាម្នាក់គ្រោះថ្នាក់ ឬស្លាប់ដោយសារយើងមិនបានយកចិត្តទុកដាក់ដោះស្រាយនោះទេ។

រដ្ឋបាលខេត្ត ដោយមានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការ បានយកចិត្តទុកដាក់ការបើកផ្តល់ប្រាក់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន ០៤ គឺកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជម្ងឺកូវីដ-19, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ សម្រេចបានដូចខាងក្រោម៖

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំសរុបចំនួន **៧.៦៨១**នាក់ មានទឹកប្រាក់ សរុបចំនួន **៣.៣១៧.៨០០.០០០**រៀល។
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជម្ងឺកូវីដ-19 សរុបចំនួន **៣៨.៩០១**គ្រួសារ មានទឹកប្រាក់ សរុបចំនួន **១៩៤.៣៧៦.៥៩៦.០០០**រៀល។

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា សរុបចំនួន ២៦.៥៩៨គ្រួសារ មានទឹកប្រាក់ សរុបចំនួន ៣.៥៥៦.១៦៨.១០០រៀល (លើកទី ១)។

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ សរុបចំនួន ៤.៧២០គ្រួសារ មានទឹកប្រាក់ សរុបចំនួន ៧៤៦.០៨០.០០០រៀល។

- ផ្តល់ប័ណ្ណក្រីក្រជូនប្រជាពលរដ្ឋចំនួន ៥៥.៨៨២ប័ណ្ណ ក្នុងនោះប័ណ្ណក្រីក្រប្រភេទ១ ចំនួន ២២.៤៤៩ ប័ណ្ណ និងប័ណ្ណក្រីក្រប្រភេទ២ ចំនួន ៣៣.៤៣៣ប័ណ្ណ។

**- ការងារសាសនា៖**

នៅទូទាំងខេត្ត មានទីវត្តអារាមចំនួន ៣៤៧វត្ត ក្នុងនោះវត្តគណៈមហានិកាយមានចំនួន ៣២០វត្ត និងវត្តគណៈធម្មយុត្តិកនិកាយចំនួន ២៧វត្ត ព្រះសង្ឃសរុបចំនួន ៤.៤២២អង្គ និងសាលាពុទ្ធិកសិក្សាចំនួន ៨៧សាលា។ វត្តដែលមានប្លង់កម្មសិទ្ធិកាន់កាប់អចលនទ្រព្យវត្តមានចំនួន ២១២វត្ត ក្នុងនោះមហានិយកាយចំនួន ១៩៨វត្ត និងធម្មយុត្តកនិកាយចំនួន ១៤វត្ត ។ ក្រៅពីនេះក៏នៅមានពាហិរសាសនាមួយចំនួនទៀតដូចជា គ្រឹស្ទសាសនាមានព្រះវិហារចំនួន ១៥៣កន្លែង ឥស្លាមសាសនា ២០កន្លែង សាសនាមហាយាន ០៨កន្លែង និងសាលាសាសនាចំនួន ៨៥កន្លែង។

## ១៥.ទិសដៅភារកិច្ចបន្ត

១-ពង្រឹងការងារសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ

២-ពង្រឹងនិងជម្រុញការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់ មានសុវត្ថិភាព

៣-ជំរុញការងារផលិតកម្ម កសិកម្ម សំខាន់ការបង្កបង្កើនផលស្រូវវស្សាប្រាំង និងវស្សា វស្សាឲ្យគ្រប់ និងលើសផែនការព្រមទាំងជម្រុញចលនាដាំដុះ ចិញ្ចឹមសត្វ បង្កង ត្រី ជាលក្ខណៈសហគម និងគ្រួសារ ។

៤-អនុវត្តកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៣-២០២៥ ឱ្យបានទាន់ពេលប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព។

៥-អនុវត្តប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

៦-ពង្រឹងការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ទាំងនៅក្នុងក្រុងទីប្រជុំជន និងជនបទដាច់ស្រយាលឲ្យបានល្អប្រសើរ។

៧-បន្តការរៀបចំវេទិកាសាធារណៈ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ សុវត្ថិភាព នៅថ្នាក់ ក្រុង ស្រុក និងឃុំ សង្កាត់ ។

៨-បង្ការបង្ក្រាប និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទ សំខាន់ការក្តាប់ជាប់មុខសញ្ញា ជនល្មើស ធ្វើការស្រាវជ្រាវជនល្មើសមិនឲ្យធ្វើសកម្មភាពបាន។

៩-យកចិត្តទុកដាក់ការងារដឹកនាំត្រួតពិនិត្យនិងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក។

១០-រៀបចំសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រ និងការវិវឌ្ឍន៍នៃការគ្រប់គ្រង ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់។

១១-ពង្រីករាល់សកម្មភាពការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ឲ្យកាន់តែមានប្រសិទ្ធភាព និង គុណភាព សំដៅលើក កម្ពស់ការយល់ដឹងទូទៅរួមចំណែកកាត់ បន្ថយភាពក្រីក្រ និង លើកកម្ពស់ជីវភាពរស់នៅ សុខុមាលភាព សេចក្តីថ្លៃថ្នូរ

និង សុវត្ថិភាពរបស់ប្រជាពលរដ្ឋ។

១២-ពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និង ផ្នែកឯកជននានា ដើម្បីជួយដល់ការអភិវឌ្ឍន៍នៅមូលដ្ឋាន។

១៣-ត្រៀមគ្រប់មធ្យោបាយជួយសង្គ្រោះប្រជាពលរដ្ឋដែលជួបគ្រោះមហន្តរាយនានាជាយថាហេតុ។

១៤-បន្តយកចិត្តទុកដាក់អភិវឌ្ឍន៍ស្ថាប័ននិងការកសាងសមត្ថភាពនៅរដ្ឋបាលខេត្តក្រុងស្រុកនិងឃុំ សង្កាត់ ។

១៥-យកចិត្តទុកដាក់ថែរក្សាបរិស្ថានឲ្យបានល្អតាមគោលការណ៍( ទីក្រុងស្អាតរមណីយដ្ឋានស្អាតសេវាល្អ)។

១៦-បន្តការផ្សព្វផ្សាយដើម្បីទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទសំខាន់ដូចជាជំងឺផ្តាសាយបក្សី(H5N1)និងប្រភេទថ្មី(H7N9)ជាពិសេសជំងឺកូវីដ ១៩ ។

១៧-ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំដើម្បី ធានាបាននូវការគ្រប់គ្រងប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព និងចូលរួមទប់ស្កាត់បញ្ហាទំនាស់ដីធ្លី។

១៨-បន្តជ្រោមជ្រែង និងផ្តល់យោបល់ជូនគណៈអភិបាលខេត្តក្នុងការជួយធ្វើឱ្យមានកំណើនសេដ្ឋកិច្ចក្នុងខេត្ត។

១៩-ផ្តល់យោបល់ និងកំណត់ទិសដៅខេត្តក្នុងការពង្រីកថាមពលអគ្គីសនី និងទឹកស្អាត។

២០-តាមដាន ត្រួតពិនិត្យការអនុវត្ត និងចូលរួមប្រឡងប្រណាំងទីក្រុងស្អាត សំដៅទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យមហាប្រសើរថ្លៃថ្លាជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅក្នុងសន្និសីទសារព័ត៌មាននាថ្ងៃនេះ សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!